# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

លេខ:...៧៧...សសរ

## សេចក្តីសម្រេចបន្ថែម

## ស្តីពី

## ការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៩៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទំរង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- បានឃើញសេចក្តីសម្រេចលេខ ២០ សសរ. ចុះថ្ងៃទី ៣០ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភា
- យោងតាមតម្រូវការចាំបាច់ នៃការងារ

## ស ម្រេ ច

ប្រការ ១ : តែងតាំង :

១- ឯកឧត្តម ក្រាញ់ ជ័យលាភីតូនី សមាជិកក្រុមប្រឹក្សាអ្នកច្បាប់

២-លោក ហ៊ីង ធីឫទ្ធិ ចៅក្រមតុលាការក្រុងភ្នំពេញ

៣-លោក សេង ស៊ីវុត្ថា ប្រធាននាយកដ្ឋានព្រហ្មទណ្ឌ និងអនុគ្រោះទោសក្រសួងយុត្តិធម៌

៤-លោក ផូវ សំភី ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ ក្រសួងយុត្តិធម៌

ជាអនុប្រធានលេខាធិការដ្ឋានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តសទ្ទានុក្រមពាក្យច្បាប់ បន្ថែមលើសេចក្តីសំរេចលេខ ២០ សសរ.ចុះថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៣។

**ប្រការ ២** : គណៈកម្មការបណ្ឌិតសភា លេខាធិការដ្ឋាន ព្រមទាំងសាមីខ្លួន មានភារកិច្ចអនុវត្តសេចក្តីសម្រេចបន្ថែមនេះ។

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ ១១ ឆ្នាំ ២០០៣

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ចម្លងជូន :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័នរដ្ឋ
- គណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ✓ រាជកិច្ច
- ឯកសារ-កាលប្បវត្តិ